# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការក្រសួងយុត្តិធម៌
លេខ ៣២៣ ព្រទ-២០០០

## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**ជម្រាបមក**

**លោកប្រធាន និងលោកព្រះរាជអជ្ញាតុលាការខេត្តស្ទឹងត្រែង**

**លោកប្រធាន និងលោកព្រះរាជអាជ្ញាតុលាការខេត្តបន្ទាយមានជ័យ**

**សូមជ្រាប។**

**កម្មវត្ថុ:** ស្តីពីការបញ្ជូនសម្រង់សាលក្រមព្រហ្មទណ្ឌទៅពន្ធនាគារ ។

**យោង:** លិខិតលេខ ៩៧០ស.ជ.ណ ចុះថ្ងៃទី០៤-១១-១៩៩៩ របស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

តាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោកប្រធាន និងលោកព្រះរាជអាជ្ញាអមតុលាការខេត្តស្ទឹងត្រែងនិងខេត្តបន្ទាយមានជ័យជ្រាបថា ដើម្បីឱ្យការរៀបចំនិងគ្រប់គ្រងទណ្ឌិតនៅក្នុងពន្ធនាគារឱ្យបានល្អនៅពេលទណ្ឌិតត្រូវផុតកំណត់ទោសនោះ លោកត្រូវបញ្ជូនសម្រង់សាលក្រមព្រហ្មទណ្ឌទៅពន្ធនាគារខេត្តនីមួយៗឱ្យបានទៀងទាត់រាល់ពេលកាត់ក្តីរួចជាស្ថាពរ ដើម្បីងាយស្រួលដល់មន្ត្រីពន្ធនាគារគ្រប់គ្រងទណ្ឌិតទាំងអស់នេះ ។

អាស្រ័យហេតុនេះ សូមលោកយកចិត្តទុកដាក់អនុវត្តចំពោះបញ្ហានេះដើម្បីជៀសវាងបញ្ហាដែលប៉ះពាល់ដល់សិទ្ធមនុស្ស សិទ្ធទណ្ឌិតផងដែរ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០០០

**ជ.រដ្ឋមន្ត្រី**

<u>ចម្លងជូន</u>

-តុលាការព្រះរាជអាជ្ញាគ្រប់ខេត្តក្រុង

-ឯកឧត្តមសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

-ឯកសារ